# ហេតុអ្វីមានពិធីចូលឆ្នាំប្រពៃណីចិននៅកម្ពុជា?

ប្រទេសចិន គឺជាប្រទេសអារ្យធម៌បុរាណមួយក្នុងចំណោមប្រទេស ដែលមានអារ្យធម៌បុរាណចំនួនបួន រួមមាន ចិន បាប៊ីឡូន ឥណ្ឌា និងអេហ្ស៊ីប។ បើយោងតាមអ្នកប្រាជ្ញចិន Liang Qichao (១៩00)។ វាមានការពង្រីកវិសាលភាពដ៏ធំធេង និងផ្សេងៗពីគ្នា ដូចជាការពង្រីកភូមិសាស្ត្រ ៣,៦00 ឆ្នាំ នៃប្រវត្តិសាស្ត្រដែលត្រូវបានកត់ត្រាក៏ដូចជា វប្បធម៌ដ៏សម្បូរបែប និងស៊ីជម្រៅ។ វប្បធម៌ចិនមានភាពចម្រុះ និងប្លែកពីគេ ប៉ុន្តែត្រូវបានបញ្ចូលចម្រុះគ្នាដែលជាទ្រព្យសម្បត្តិមិនអាចកាត់ថ្លៃបានសម្រាប់ពិភពលោក។ វប្បធម៌ចិនទាំងនោះមានដូចជា **ប្រពៃណីបេតិកភណ្ឌ សិល្បៈ ពិធីបុណ្យ ភាសា** និង**និមិត្តសញ្ញា**។ រួមបញ្ចូលទាំងម្ហូបអាហារចិន តំបន់បេតិកភណ្ឌពិភពលោក **ពិធីបុណ្យនិទាឃរដូវ(ចូលឆ្នាំចិន= China's Spring Festival or Luna)**របស់ប្រទេសចិន កុងហ្វូ និងល្ខោនអូប៉េរ៉ាប៉េកាំង(Beijing opera)។[1]

បើក្រឡេកមើលពីប្រវត្តិសាស្ត្រតាមរយៈឯកសាររបស់លោក Adreas Reinede និងSeng Sonetra ដែលសរសេរអំពីThe first Golden age of Cambodia បានបង្ហាញថា ដែនដីកម្ពុជានេះមានទំនាក់ទំនងជាមួយចិនតាំងពីមុន គ.ស។ វត្តមាននៃរចនាបទមាស ជាពិសេសជញ្ជៀនត្រារូបសេះ ដែលគេរកឃើញនៅស្ថានីយ៍មួយ នៅខេត្តព្រៃវែង ដែលមានអាយុកាលប្រហែល សតវត្សទី១មុន គ. ស។ នៅស.វទី៣នៃគ.សគឺ ការមកដល់នៃជនជាតិចិនឈ្មោះ ជូ យីង(Zhou Ying) និងកាំង ថៃ(Kang tai)។ យើងអាចដឹងរឿងរ៉ាវប្រវត្តិសាស្ត្រនៃនគរហ្វូណនមួយចំនួនតាមរយៈជនទាំងពីរនេះ។[2]

## ១.ការតាំងលំនៅរបស់ជនជាតិចិននៅកម្ពុជា

កំណត់ត្រាដំបូងបំផុតនៃការតាំងទីលំនៅរបស់ប្រជាជនចិននៅកម្ពុជា គឺចាប់តាំងពីចុងសតវត្សរ៍ទី១៣ ។ នៅពេលដែលបេសកជនចិនឈ្មោះ **ជូតាក្វាន់** មកទស្សនាកម្ពុជានៅក្នុងឆ្នាំ១២៩៦ គាត់បានកត់ត្រាថា មានវត្តមានរបស់ប្រជាជនចិននៅតំបន់អង្គរ។ ជាច្រើនឆ្នាំក្រោយមក នៅដើមទសវត្សរ៍ឆ្នាំ១៦០០ អ្នកដើរសមុទ្រជនជាតិព័រទុយហ្គាល់ បានកត់ត្រាថា មានប្រជាជនចិនបានតាំងទីលំនៅក្នុងរាជធានីភ្នំពេញ។ នៅអំឡុងពេលដូចគ្នានេះដែរ លោកលីម តូ ខៀង (Lim To Khieng) អ្នកជំនួញឯកជនចិនម្នាក់ ក៏បានសង្កេតឃើញដូចគ្នានេះដែរ ក្នុងអំឡុងពេលដែលគាត់បានមកដល់ប្រទេសកម្ពុជាដើម្បីធ្វើជំនួញ។[3] បន្ទាប់ពីការដួលរលំនៃរាជវង្សមីងនៅក្នុងឆ្នាំ១៦៤៤ ឧត្តមសេនីយ៍ចិន ស្ថិតនៅក្រោមការទំនុកបម្រុងពី Mac Cuu និង Duong Ngan Dich បាននាំជនភៀសខ្លួនចិនជាច្រើននាក់ ពីខេត្តហ្វូជាន(Fujian) និង ក្វាងទុង(Guangdong)ទៅតាំងលំនៅ នៅកូសាំងស៊ីន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជា។ សូមបញ្ជាក់ថា មួយចំនួននៃជនភៀសខ្លួនទាំងនេះ ក៏បានតាំងទីលំនៅផងដែរ នៅក្នុងខេត្ត

---

1 https://www.chinahighlights.com/travelguide/culture/

2 ជនជាតិដើមភាគតិចចិននៅកម្ពុជា(បណ្ឌិត ជិន សុជាតិ លោកស្រី យាង ជានី លោកទេព វន្ថា,២០១៩,ទំព័រទី៣)

3 តើជនជាតិចិនចូលមករស់នៅលើទឹកដីកម្ពុជាតាំងពីពេលណា?https://thmeythmey.com/?page=detail&id=36148(២០១៨)

តាកែវ និង ខេត្តកំពត។ យើងឃើញថា ប្រទេសចិនត្រូវបានគ្រប់គ្រងដោយ រាជវង្សយានគឺជារាជវង្សជនជាតិដើម ម៉ុងហ្គោលនៅឆ្នាំ១២៧១–១៣៦៨ នៃគ.ស។ [4] អំឡុងពេលនោះហើយ ដែលប្រជាជនចិនបានរត់គៀសខ្លួនពីសង្គ្រាម មកតាំងលំនៅក្នុងប្រទេស វៀតណាម និង កម្ពុជាជាដើម។



រូបភាព៖ វត្តមានជនជាតិចិននៅកម្ពុជាសម័យអង្គរ

## ១.ការរស់នៅរបស់ជនជាតិចិននៅក្នុងប្រទេសកម្ពុជា

ប្រជាជនចិនដែលកំពុងមានវត្តមាននៅលើទឹកដីកម្ពុជា មានបីប្រភេទ[5]៖

ប្រភេទទីមួយ គឺ ពលរដ្ឋខ្មែរដែលមានដើមកំណើតចិន ដែលបានធ្វើចំណាកស្រុកពីប្រទេសចិនមករស់នៅលើទឹកដីកម្ពុជាតាំងពីយូរមកហើយ សព្វថ្ងៃបានក្លាយទៅជាពលរដ្ឋខ្មែរស្របច្បាប់។ ប្រភេទទីពីរ គឺ ចិនកាត់ខ្មែរ ឬ ខ្មែរកាត់ចិន គឺសំដៅយក ក្រុមមនុស្សដែលជាកូនចៅរបស់គូសម្ព័ន្ធដែលផ្សំផ្គុំឡើងរវាងចិននិងខ្មែរ (ប្តីចិន ប្រពន្ធខ្មែរ ឬ ប្តីខ្មែរ ប្រពន្ធចិន)។ ពួកគេជាប្រជាជនដែលកើតនៅលើទឹកដីកម្ពុជា និង មានសញ្ជាតិជាពលរដ្ឋខ្មែរ។ ប្រភេទទីបី គឺជាអន្តោប្រវេសន៍ចិន ដែលចូលមកស្រុកខ្មែរក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ពួកគេភាគច្រើនមកពី សិង្ហបុរី តៃវ៉ាន់ ហុងកុង និង ចិនដីគោក។ ក្នុងចំណោមពួកគេ មានមុខរបរខុសៗគ្នា ដូចជា មន្ត្រីការទូត ពាណិជ្ជករ វិនិយោគគិន គ្រូបង្រៀនភាសាចិន អ្នកផ្សាយសាសនា វិស្វករ កម្មករជំនាញជាដើម។ល។ ក្នុងការរស់របស់ពួកគេលើទឹកដីខ្មែរ បានប្រកាន់ខ្ជាប់នូវប្រពៃណីសែនព្រេនក្នុងថ្ងៃ បុណ្យចូលឆ្នាំចិន

[4] History of China: Timeline Summary, Dynasties of China, Maps ( *By Fercility Jiang Updated Jan. 19, 2022* ). *https://www.chinahighlights.com/travelguide/culture/china-history.htm*

[5] តើជនជាតិចិនចូលមករស់នៅលើទឹកដីកម្ពុជាតាំងពីពេលណា?( 10, Feb 2018 , 7:39 pm ) https://thmeythmey.com/?page=detail&id=36148

បុណ្យសែនលោកខែ បុណ្យសែនក្បាលទឹក បុណ្យឆេងម៉េង ជាទំនៀមទម្លាប់តាំងពីដើមរៀងមក។ អន្តោប្រវេសន៍ជនជាតិចិន ដែលមកដល់កម្ពុជាដំបូងៗ ភាគច្រើនបំផុតជាបុរស ហើយពួកគេបានយកស្ត្រីខ្មែរធ្វើជាភរិយា[6]។ មួយវិញទៀត ការតាំងទីលំនៅរបស់ជនជាតិចិនបានការប្រោសប្រទាន ពីព្រះមហាក្សត្រខ្មែរ មានគោលនយោបាយផ្តល់សិទ្ធិជ្រកកោនដល់ជនភៀសខ្លួនជនជាតិចិននិងជនជាតិដទៃៗទៀតតាំងពីសតវត្សទី១៣មក។ នៅសតវត្សទី១៩ ផ្អែកលើតម្លៃខាងវប្បធម៌ សេដ្ឋកិច្ច ភាពស្មោះត្រង់ និងចេះនិយាយភាសាខ្មែរបានល្អ ហើយបើពួកគេមានកំណើតនៅក្នុងប្រទេសកម្ពុជា កូន ចៅជនជាតិភាគតិចចិនខ្លះក៏ត្រូវបានតែងតាំងធ្វើជាចៅហ្វាយខេត្តផងដែរ។ ពួកគេក៏ត្រូវបានលើកទឹកចិត្តឱ្យគោរព ប្រតិបត្តិទាំងវប្បធម៌ខ្មែរ និងការប្រតិបត្តិជំនឿសាសនាតាមបែបចិន[7]។

នៅទសវត្សរ៍ឆ្នាំ១៩៦០ និង ដើមទសវត្សរ៍ឆ្នាំ១៩៧០ ជនជាតិចិនគឺ ជាក្រុមជនជាតិភាគតិចដែលមានចំនួនច្រើនជាគេបំផុតនៅកម្ពុជា ដែលមានប្រមាណ ៤២៥ ០០០ នាក់។[8] ប៉ុន្តែ ត្រឹមឆ្នាំ ១៩៨៤ ក្រុមជនជាតិភាគតិចចិន នៅសល់តែ ៦១ ៤០០ នាក់ ប៉ុណ្ណោះ។ ការថយចុះចំនួននូវក្រុមជនជាតិភាគតិចចិននេះ គឺដោយសារតែពួកគេបានចូលរួមក្នុងសង្គ្រាម,សេដ្ឋកិច្ចធ្លាក់ចុះ, ការសម្លាប់រង្គាលនៅក្នុងរបបខ្មែរក្រហម, ការភៀសខ្លួនទៅប្រទេសទីបីក្នុងសម័យសង្គ្រាម។ នៅក្នុងអំឡុងទសវត្សរ៍៨០ ជនជាតិចិនត្រូវបានគេហៅថាក្រុម«៣៥១»។ លេខ៣៥១នេះគឺសំដៅលើសហគមន៍ចិនដែលរស់នៅក្នុងប្រទេសកម្ពុជា។ ដោយសារតែ មានលំហូរចូលនូវជនអន្តោប្រវេសន៍ជនជាតិចិនមកប្រទេសកម្ពុជា នៅចុងឆ្នាំ២០១៥ ក្រសួងវប្បធម៌អនុញ្ញាតឱ្យបង្កើតបាននូវ មជ្ឈមណ្ឌលវប្បធម៌ចិននៅស្រុកខ្មែរ ជាផ្លូវការ។ មជ្ឈមណ្ឌលវប្បធម៌នេះ ជាស្ថាប័នផ្សព្វផ្សាយពីវប្បធម៌ចិន ដែលកសាងឡើង ដោយមានបណ្ណាគារភាសាចិន។ ចំពោះការរីកសាយ នៃវប្បធម៌ចិនមកលើប្រទេសកម្ពុជា បានធ្វើឱ្យប្រទេសកម្ពុជាមានពលរដ្ឋខ្មែរដែលមានដើមកំណើតចិន និង ចិនកាត់ខ្មែរ មានប្រមាណ១៥២ ០៥៥ នាក់ ស្មើ១% នៃប្រជាជនកម្ពុជាសរុប (ឆ្នាំ២០១៣)។ នៅឆ្នាំ២០១៥ ជនជាតិចិនកំពុងរស់នៅកម្ពុជា មានចំនួនប្រមាណ ១លាននាក់ និងមានសមាគមដែលរក្សាត្រកូលសំខាន់ៗបែបចិន កំពុងរស់នៅកម្ពុជា ចំនួន ១៣សមាគម(សមាគមខ្មែរចិន-២០១៥)[9]។

**១.២.ការធ្វើជំនួញ(មុខរបរ)**

ក្នុងសង្គមខ្មែរ អ្នកលក់ដូរ ឬពាណិជ្ជករ ទាំងតូច ទាំងធំ ភាគច្រើន ជាជនជាតិភាគតិចចិន ឯជនជាតិខ្មែរវិញចូលចិត្តប្រកបរបរកសិកម្ម និងធ្វើការងាររាជការ។ នាពេលបច្ចុប្បន្ន មានជនជាតិខ្មែរភាគច្រើន បានប្រកបរបរជំនួញដូរ ដូចជនជាតិភាគតិចចិន ហើយក៏រៀនគ្រាប់តាមចិន ព្រោះចង់បានឈ្មោះជាកូនចៅអ្នកជាប់សែស្រឡាយចិន ឬកូនចៅចិន។ ព្រោះមើលឃើញថា ជនចិនដែលមករកស៊ីឬធ្វើជំនួញនៅកម្ពុជា មានសេដ្ឋកិច្ចគ្រួសាររីកចម្រើន ហើយនៅពេលរដូវបុណ្យប្រពៃណីចូលឆ្នាំចិន គេតែងតែឃើញ ជនជាតិចិនធ្វើពិធីសែនព្រេនតាមបែបប្រពៃណី

[6] ឥទ្ធិពលជនជាតិចិននៅកម្ពុជា» ដោយ បណ្ឌិត ឈត ប៊ុនថង ប្រធានផ្នែកទំនាក់ទំនងវប្បធម៌ អប់រំ និងទេសចរណ៍ នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា(២០១៩)
[7] ភាពសុខដុមរមនានៃក្រុមជនជាតិភាគតិចចិននៅកម្ពុជា( ហៀង លាងហុង,2018)៖ វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា
[8] William E. Willmott, The Chinese in Cambodia, 1967.
[9] ហេតុអ្វីបានជាវប្បធម៌ចិនមានឥទ្ធិពលខ្លាំងមកលើប្រទេសកម្ពុជា?(ដោយ អាន ស៊ីថាវ2015-02-19)

ចិន ដើម្បីសុំសេចក្តីសុខ និងការរកទទួលទានមានជោគជ័យនៅឆ្នាំទៅមុខទៀត។ ម្យ៉ាងទៀត អន្តោប្រវេសន៍ចិនភាគច្រើនស្ទើរតែគ្រប់សម័យកាលត្រូវបានទទួលស្គាល់ថាជាអ្នកមានទេពកោសល្យខាងការធ្វើជំនួញជួញដូរ។ ប៉ុន្តែអ្នកស្រាវជ្រាវខ្លះមានទស្សនៈថា ភាពស្ទាត់ជំនាញខាងសេដ្ឋកិច្ចក្នុងចំណោមជនជាតិចិន ទាំងឡាយគឺមិនមែនជាចរិតលក្ខណៈរបស់ពួកគេតាំងពីកំណើតនោះឡើយ។ ជាទូទៅពួកគេរៀនជំនាញនេះពីបទ ពិសោធន៍ដែលពួកគេបានជួបប្រទះពេលបានមករស់នៅលើទឹកដីថ្មី និងសមត្ថភាពក្នុងការកែច្នៃធម្មជាតិបានធ្វើឱ្យ ពួកជនជាតិចិនទាំងនោះពូកែធ្វើជំនួញ។ ទន្ទឹមនឹងនេះ ផែនការរបស់ពួកអាណានិគមលើវិស័យសេដ្ឋកិច្ច និងតម្រូវការ ប្រើប្រាស់កម្លាំងពលកម្ម ក៏ជាកត្តាកំណត់បានជំរុញឱ្យពួកជនជាតិចិនខិតខំស្វែងរកជំនាញខាងធ្វើជំនួញផងដែរ។

ដោយសារតែភាពវៃឆ្លាតរបស់ក្រុមជនជាតិភាគតិចចិន ស្ទើរតែគ្រប់សម័យកាលពួកគេបានគ្រប់គ្រងវិស័យជំនួញគ្រប់ប្រភេទនស្រុកខ្មែរ ហើយសកម្មភាពជំនួញរបស់ពួកគេនៅតែបន្តរហូតសព្វថ្ងៃ។ តាំងពីសម័យមុនរហូតបច្ចុប្បន្នជនជាតិភាគតិចចិននៅតែមានតួនាទីសំខាន់ក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា។ ពួកគេបានកាន់កាប់ទីផ្សារសេដ្ឋកិច្ចទាំងនៅទីក្រុង និងខេត្តសំខាន់ៗប្រហែល៩០% ខណៈប្រជាជនខ្មែរភាគច្រើននៅបន្តប្រកបរបរកសិកម្មដោយប្រើកម្លាំងកាយ( ហៀង លាងហុង,២០១៨,ទំព័រទី៨)។

អត្ថបទកាសែតក្នុងស្រុកខ្លះក្នុងសម័យអាណានិគម ក៏បានទទួលស្គាល់នូវគំនិតដ៏ប៉ិនប្រសប់ និងឧស្សាព្យាយាមរបស់ជនជាតិភាគតិចចិនមានតួនាទីជាគំរូសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ជនជាតិខ្មែរតែងសរសើរថា ជនជាតិចិនមកស្រុកខ្មែរដោយបាតដៃទទេគ្មានដើមទុនអ្វីទាល់តែសោះ ប៉ុន្តែ ពេលមកដល់ស្រុកខ្មែរ មិនយូរប៉ុន្មានក៏បង្កើតបានមុខរបរនិងជំនួញធំៗបាន( ហៀង លាងហុង,២០១៨,ទំព័រទី៩)។



រូបភាពការធ្វើជំនួញរបស់ជនជាតិចិន

## ៣.សន្និដ្ឋាន

តាមប្រវត្តិសាស្ត្រដូចដែលបានលើកឡើងនូវចំណុចខាងលើ បានបង្ហាញថា ប្រទេសកម្ពុជានិងចិនមានទំនាក់ទំនងជាមួយគ្នាតាំងពីសតវត្សទី១មុនគ.ស និងការមកតាំងលំនៅរបស់ជនជាតិចិននៅលើទឹកដីកម្ពុជានៅសតវត្សទី១៣ និង ទសវត្សរ៍ឆ្នាំ១៩៦០ និង ១៩៧០ រហូតដល់ឆ្នាំ២០១៣ និងវត្តមានជនជាតិមករស់នៅលើទឹកដីកម្ពុជា នៅសម័យសន្តិភាព ឬអាចហៅម្យ៉ាងទៀតថា សម័យសង្គមឌីជីថល ឬបដិវត្តឧស្សាហកម្ម ៤.០ ។ នេះ

សបញ្ជាក់ឱ្យឃើញថា ប្រពៃណី វប្បធម៌របស់ចិនគឺមាននៅលើទឹកដីប្រទេសកម្ពុជា ពិសេសនោះគឺ ការប្រារព្ធពិធីបុណ្យចូលឆ្នាំចិន នៅកម្ពុជាកើតមានជាយូរយារណាស់មកហើយ។ មួយវិញទៀត ដោយសារតែ ជនជាតិចិនមានទំនាក់ទំនងល្អជាមួយពលរដ្ឋកម្ពុជា បង្កើតបានជាចំណងអាពាហ៍ពិពាហ៍ តពូជពង្សវង្សត្រកូល បង្កើតបានជាការគោរពនូវប្រពៃណីទំនៀមទំលាប់ចិនរៀងមក នេះជាឥទ្ធពលនៃការគោរពជូនតារបស់ជនជាតិខ្មែរ សែស្រឡាយចិន (ខ្មែរ ចិន) រួមទាំងកំណើននៃវិនិយោគិនរបស់ចិន ផងដែរ។ ភាពប៉ិនប្រសប់ក្នុងការធ្វើជំនួញរបស់ជនជាតិចិន បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរយល់ឃើញថា ការសែនព្រេនក្នុងគ្រប់ពិធីទាំងអស់របស់ចិន មិនថា ពីធីចូលឆ្នាំ សែនក្បាលទឹក សែនលោកខែ ឬឆេងម៉េង តាមប្រពៃណីទំនៀមទម្លាប់ចិន គឺសុទ្ធតែអាចធ្វើឱ្យពួកគេរកស៊ីមានបានទាំងអស់។ ពួកគេភ្លេចគិតថា៖ "ចេះគឺមកពីរៀន ហើយមានគឺមកពីខិតខំរក" មនុស្សកើតមកមិនដែលចេះឯង ត្រូវចេះគិតគ្រប់កន្លែង កុំដេកតែក្រ។ ភាពមានបាន មិនមែនដោយសារតែការសែនព្រេននោះទេ។ គឺបានមកពីការខិតខំរក និងសំចៃទុក កុំប្រឹងចាយពេក ដូចកាលពីលោកតាភិរម្យភាសាអ៊ូ នៅរស់ គាត់បានប្រដៅថា៖ "**ឯង(ខ្មែរ)ចេះតែកិន ចិនចេះតែកត់ ផឹកដល់កំណត់ យកស្រែបញ្ចាំ**"។

សរុបមក វត្តមានពិធីចូលឆ្នាំប្រពៃណីចិននៅកម្ពុជា គឺបណ្តាលមកពីពលរដ្ឋខ្មែរសែស្រឡាយចិន ដែលចង់បង្ហាញពីការប៉ិនប្រសព្វនៃការធ្វើជំនួញ ចង់ឆ្លុះបញ្ចាំងពីភាពមានបានរបស់ខ្លួន លើទឹកដីកម្ពុជា។

បញ្ជាក់៖ ការលើកឡើងទាំងនេះគឺជា គំនិតមួយជ្រុងតែប៉ុណ្ណោះ ដែលជាអំណះអំណាង និងជាទឡ្ហីករណ៍ក្នុងការគាំទ្រនូវប្រធានបទនេះ។ បើសិនជាមានចំនុច មិនត្រឹមត្រូវសូមជួយកែតម្រូវដោយក្តីអនុគ្រោះផង៕

ដោយលោក ហៃ សុវង្ស
មន្ត្រីស្ម័គ្រចិត្តនៃវិទ្យាស្ថានសិក្សាចិន
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ៤. ឯកសារយោង៖


១.https://www.chinahighlights.com/travelguide/culture/

២. ជនជាតិដើមភាគតិចចិននៅកម្ពុជា(បណ្ឌិត ជិន សុជាតិ លោកស្រី យាង ធានី លោកទេព វន្ធា,២០១៩,ទំព័រទី៣)

៣. តើជនជាតិចិនចូលមករស់នៅលើទឹកដីកម្ពុជាតាំងពីពេលណា?https://thmeythmey.com/?page=detail&id=36148(២០១៨)

៤. History of China: Timeline Summary, Dynasties of China, Maps ( *By Fercility Jiang Updated Jan. 19, 2022*). *https://www.chinahighlights.com/travelguide/culture/china-history.htm*

៥. តើជនជាតិចិនចូលមករស់នៅលើទឹកដីកម្ពុជាតាំងពីពេលណា?( 10, Feb 2018 ,) https://thmeythmey.com/?page=detail&id=36148

៦. ឥទ្ធិពលជនជាតិចិននៅកម្ពុជា» ដោយ បណ្ឌិត ឈត ប៊ុនថង ប្រធានផ្នែកទំនាក់ទំនងវប្បធម៌ អប់រំ និងទេសចរណ៍ នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា(២០១៩)

៧. ភាពសុខដុមរមនានៃក្រុមជនជាតិភាគតិចចិននៅកម្ពុជា( ហៀង លាងហុង,2018)៖ វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា

៨. William E. Willmott, The Chinese in Cambodia, 1967.

៩. ហេតុអ្វីបានជាវប្បធម៌ចិនមានឥទ្ធិពលខ្លាំងមកលើប្រទេសកម្ពុជា?(ដោយ អាន ស៊ីថាវ2015-02-19)